ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ៣១៣៨ ព.ណ.ករណ

ថ្ងៃពុធ ២កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០២២

**<u>ជម្រាបមក</u>**

**លោកប្រធានក្រុមហ៊ុន អេច ជី ប៊ី ហ្វ៊ូដ អិនជាសស្ទ្រី**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខលើផលិតផលទឹកពិសារដែលមានជាតិរ៉ែ ទឹកផ្លែឈើ ទឹកបន្លែ និងភេសជ្ជៈដែលគ្មានជាតិអាល់កុលម៉ាក "VOLVIC" របស់ក្រុមហ៊ុន **អេច ជី ប៊ី ហ្វ៊ូដ អិនជាសស្ទ្រី** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**- មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតស្នើសុំរបស់ក្រុមហ៊ុន **អេច ជី ប៊ី ហ្វ៊ូដ អិនជាសស្ទ្រី** ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០២២
- លិខិតប្រគល់សិទ្ធិផ្ដាច់មុខរបស់ក្រុមហ៊ុន SOCIETE DES EAUX DE VOLVIC ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០២២
- លិខិតប្រគល់សិទ្ធិផ្ដាច់មុខរបស់ក្រុមហ៊ុន Soctiété Anonyme des Eaux Minérales d'EVIAN (SAEME) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៨៦២៧២/២១ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានក្រុមហ៊ុនថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខលើផលិតផលទឹកពិសារដែលមានជាតិរ៉ែ ទឹកផ្លែឈើ ទឹកបន្លែ និងភេសជ្ជៈដែលគ្មានជាតិអាល់កុលពាក់ម៉ាកខាងលើ របស់ក្រុមហ៊ុន **អេច ជី ប៊ី ហ្វ៊ូដ អិនជាសស្ទ្រី** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន SOCIETE DES EAUX DE VOLVIC ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខនេះមានសុពលភាពត្រឹមថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២៣ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន SOCIETE DES EAUX DE VOLVIC ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្ដាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោកប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

***<u>ចម្លងជូន:</u>***
*- ទីស្ដីការគណៈរដ្ឋមន្ត្រី*
*- ខុទ្ទកាល័យ **សម្ដេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
*- ខុទ្ទកាល័យ សម្ដេចក្រឡាហោម **ស ខេង***
*- ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
*- ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*- អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
*- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
*-អគ្គនាយកដ្ឋានពន្ធដារ*
*- ឯកសារ - កាលប្បវត្តិ*

ក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

អ៊ុក-ប្រជា

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469